ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

គម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ

លេខ ៦

សមាជិកក្រុមឈានល្អឃើញគេពិសល់ដង្ហើមផ្ដិតទ ក៏នាំគ្នារើសអាវុធចាកចេញពីទីនោះ ដោយឥតរវល់មើលសៃយានទីឡើយ ៗ ជនសំគមយាវដៃស្ដាំទះដើមឈើផាំង កាំបិតនៃជនមុខអាក្រក់ដែលគប់ក្នុងសាច់ឈើដកមិនទាន់រួចនោះ ក៏ខ្ទាតចេញមកយ៉ាងឆ្ងាយ, ជនមុខអាក្រក់លូកដៃចាប់ជាប់សើចក្អាកក្អាយ ហើយដើរចេញទៅ ៗ

សៃយានទីជ្រួញចិញ្ចើមនឹកថា !

–ជនទេះមានត្រកូលនិងក្រុមឈានល្អ ព្រះគុណដាវរហ័សរហួនណាស់, តែស្នៀតទះដើមឈើឲ្យខ្ទាតកាំបិតមុខក្រាស់ដូចជាពិបាកធ្វើណាស់... ក្រែងគេបង្កប់យើងទេដឹង?

ពេលដដែលនេះកុមារត្រដោលពោលទៅកាន់តាពៃ :

–លោកតា . . . ចាំខ្ញុំរបួសឲ្យ ៗ

រារើសកំណាត់អាវមករុំមុខរបួសឲ្យតាចាស់យ៉ាងផ្ចិតផ្ចង់ តាពៃញញួចក្អកពោលខ្សាវៗ :

–ឥតប្រយោជន៍ទេ . . . ក្នុងពោះចៅតាមាន . . . មានកូនគក្កតាធ្វើពីដីខ្វះ ឯងយកចុះ ...

ពេលបានតែប៉ុណ្ណោះ តាពៃទន់កន្ទៀងក្បាលទៅម្ខាង ដាច់ខ្យល់ក៏ង, ទន់ជង្គង់សន្សឹមៗមកដល់ដី ៗ . កុមារក៏សង្កត់ចាប់

គាត់អង្រួនផង ស្រែកហៅផងថា តា ! តា !

តាពៃស្លាប់ទៅហើយ, សែយានទីដើរចេញមកឆ្លើយជំនួស :

-គាត់ស្លាប់ហើយ តែអម្បាញ់មិញគាត់ប្រាប់ឯងថាម៉េច ?

គាត់ថាក្នុងហោប៉ៅមានកូនតុក្កតា ឲ្យខ្ញុំយកចុះ ។

សែយានទី នឹកថា តាពៃជាអ្នកក្លាហានក្នុងពិភពគុន មានគម្រិះវិជ្ជាខ្ពង់ខ្ពស់ស្មើគាត់ដែរ មិនលែងមានរបស់សំខាន់ក្នុងហោប៉ៅទេ ។ ប៉ុន្តែគាត់មិនទម្លាប់ខ្លួនរើកកាយហោប៉ៅខោអាវខ្មោច ទើបធ្វើព្រងើយពោលសួរកុមារកន្ទក់វិញ :

- បើគាត់ឲ្យហើយម៉េចក៏ឯងមិនយកមកមើល ?

កុមារសួរបញ្ជាក់ :

- ខ្ញុំយកបែបហ្នឹង គេមិនហៅកូនចោរទេឬ ?

សែយានទីសើច :

- មិនមែនកូនចោរទេ , អានាង ។

កុមារលូកដៃក្នុងហោប៉ៅសពយកបានប្រអប់ឈើមួយ និង ក្រាតពីរបីគម្ពីង , អាវុធសម្ងាត់មានបន្ទះនិង ក្រដាសពីរបីសន្លឹក រាងដូចគំនូរផែនទី ។

សែយានទីចង់មើលរូបនោះណាស់ តែគាត់មិនដាច់ចិត្តលូកដៃយកពីកុមារគ្រោះខ្លាចថារាំពោរ ផ្តេសផ្តាសនាំខ្មាសរាំទៀត ម្ល៉ោះហើយគាត់បេះតែឈរមើលនៅស្ងៀម ។ កុមារបើកប្រអប់ឃើញកូនតុក្កតាឈរលើសំឡីបីជួរ មួយជួរមានចំនួន ៦ ទាំងអស់ត្រូវជា ១៨ ។ តុក្កតាទាំងអស់ធ្វើពីដីឥដ្ឋយ៉ាងផ្ចិតផ្ចង់ដូចមនុស្សស្រាត ហើយបានលាបកំបោរសក្បុស ថែមទាំងមានគូសរសៃឈាមក្រវែមក្រាមផង ។

សែយានទីស្គាល់ច្បាស់ជាសរសៃជីពចរនៃខ្លួនមនុស្ស ហើយកូនតុក្កតាទាំង១៨ នេះពិតជាគំរូសម្រាប់ហាត់រៀនវិជ្ជាចំរើនកម្លាំងធាតុ ព្រមទាំងក្បួនខ្ទាតឯទៀតខាងក្រុមកោះត្រីថ្លាបហើយ, តាពៃរំភើបចិត្តនឹងអាតូបក្លាហានដែលហ៊ានយកខ្លួនពាំងមុខគាត់ការពារមិនឲ្យសត្រូវប្រហារ ទើបឲ្យរាំយកប្រអប់នេះទុកជាអនុស្សាវរីយ៍ ។

យានទីនឹកថា បើកញ្ចាស់ឯងមិនឲ្យក៏រាំកាវយកទៅលេងតាមនិស្ស័យក្មេងដែរ ។ សែ

យានទឹយល់ប្រឡំស្រឡះ ព្រោះក្មេងនេះមិនដូចក្មេងដទៃសោះឡើយ កាលណាគេមិនឲ្យវាមិនយកទេ ។ ប្រសិនបើគាត់មិនប្រាប់វាឲ្យយក វាឥតហ៊ានលូកហោប៉ៅគាត់ទេ ទោះចង់លេងតុក្កតាយ៉ាងណាក៏ដោយ ។

ពេលនេះកុមារកំសត់សម្លឹងតុក្កតាទាំង ១៨ ម្តងមួយៗពោលសរសើរមិនដាច់ពីមាត់:

-យីដូចមនុស្សមែនទែនអ៊ីចឹង! សប្បាយណាស់! ម៉េចគេមិនស្លៀកពាក់ឲ្យវាផងហ្ន៎ ?

សៃ យានទឹក្រឡេកមើលសពគាត់ពេតឹកថា :

- កញ្ចាស់នេះឥតត្រូវរ៉ូវជាមួយយើងសោះ ។ ប៉ុន្តែគេជាអ្នកក្លាហានក្នុងពិភពគុនដែរមិនត្រូវពោលសាកសពឲ្យគ្មានស៊ីឡើយ ។

គាត់នឹកឃើញមធ្យោបាយមួយភ្លាមញញឹមខ្ចឹបអង្គុយ ពោងហោងមើលក្មេងតូចកំពុងលេងតុក្កតា ។

## ចង្កូទី ៦

## ចិត្តកាចសាមាន្យ

សៃ យានទឹសម្លឹងក្មេងមួយសន្ទុះ ទើបសួរ :

- នែអានាង គាឯងស្លាប់ហើយ មិនគិតកប់ខ្មោចគាត់ទេហ : ?

- អូមែន! គេកប់ខ្មោចយ៉ាងម៉េចទៅ ?

សៃ យានទឹពោលព្រងើយ :

- បើមានកម្លាំងត្រូវជីកដីធ្វើរណ្តៅកប់, បើអន់ខ្សោយដូចឯង, គ្រាន់តែកាយដីនិងថ្មដាក់ពីលើក៏បានដែរ ។

- យី! កន្លែងនេះគ្មានចបទេ ជីករណ្តៅម្តេចកើត ?

សៃយានទឹអរកើត នឹកថា ពេលនេះអាតូចគ្រាំមិនបានទេ, វាហៅគាត់ឲ្យជួយឥឡូវហើយ ។ ប៉ុន្តែកុមារនេះមានចិត្តមានះ និងក្លាហានណាស់, វាមិនខ្ចីហាមាត់អង្វរ ឬហៅគាត់ជួយឡើយ សុខចិត្តប្រមែប្រមូលដុំថ្ម មែកឈើនិងស្លឹកឈើគ្របពីលើសពគាត់ពេតាល់តែជិត ហាត់បែកញើសតយៀវ ។ សៃ យានទឹដាច់មេត្តាអស្ចារ្យក្រពាត់ដៃឈរមើលទាល់តែចប់ ទើបបញ្ចូលវាចេញដំណើរតទៅទៀត ។ កុមារនេះប្រកែក:

-ទៅណា ? ខ្ញុំមិនទៅជាមួយអ៊ំទេ, ហត់ណាស់ ។

-ម៉េចឯងមិនទៅជាមួយយើង ?

-ខ្ញុំចង់ទៅរកម៉ែនិងអាវួងវិញ ។

ស៊ីយានទីក្តុកក្តួលខ្លាំងឡើង ទទឹងឲ្យតែក្មេងតូចពោលពាក្យអង្វរគាត់ និងអាលបែកផ្លូវគ្នាដើរ ។ គាត់នឹកថា :

-យើងសច្ចាថា មិនធ្វើបាបហើយមិនបង្ខំជនណាដែលប្រគល់បញ្ជាដែកសំរិទ្ធ ដល់ដៃយើងទេ, តែយើងឥតតមរឿងកុហកឡើយ, ឥឡូវគ្មានផ្លូវដោះស្រាយក្រៅពីកុហកទេ ។

គិតហើយគាត់ពោលឲ្យរួចពីមាត់ :

- ឯងទៅជាមួយយើង, យើងជួយរកម្ដាយឯងនិងអាវួង ។

កុមារគេងក់តបយ៉ាងរីករាយ :

- អូ! អ៊ំពូកែយ៉ាងហ្នឹងច្បាស់ជារកម៉ែខ្ញុំ និង អាវួងឃើញហើយ !

ស៊ីយានទីនឹកថា និយាយច្រើនឥតបានប្រយោជន៍ទេ , បើឯងមិនអង្វរ យើងមិនខ្វល់រកម្ដាយឯងដែរ ព្រោះមិនដឹងរកកន្លែងណា ?

គាត់ដឹកដៃកុមារគៀន :

-ទៅឆាប់ឡើង !

ក្មេងតូចឆ្លើយបាទ ! ស៊ីយានទីចាប់បង្កើនជំហានដើរពីដីតំលើនរឹងដូចគេហោះ ។ កុមារនេះសប្បាយណាស់ត្រូវខ្យល់បក់ដូចគេហោះកណ្ដាលអាកាសកំសើចហាសៗ ចប់តាមផ្លូវ ។ ក៏ឃើញដើមឈើ និងព្រៃព្រឹក្សាតវៗជាប់គ្នារដឹក ក៏សាកសួរស៊ីយានទី :

- អ៊ំអ្ហា ! អ៊ំបេះហោះឬ ?

ស៊ីយានទីកៀបកុមារត្រដោលសម្រាលខ្លួនរត់ហូតដល់ព្រលប់ដល់ព្រៃជ្រៅទើបឈប់សំរាក ។ គ្មានតែលែងដៃភ្ញាមកុមារកំសត់ទន់ជង្គង់ដួលអុកតូចទឹស ។ បានមួយស្របក់ស្រាប់តែបាត ជើងវាឈឺខ្លាំងៗ រួចហើមបន្តិចម្ដងៗឡើងក្រហមរលោង ។ វាស្រែកដោយភ្ញាក់ :

- អ៊ំអើយ ជើងខ្ញុំហើមធំណាស់ ។

ស៊ីយានទីងាកមកពោលធ្វើហី :

-បើឯងអង្វរយើងឲ្យជួយ, យើងព្យាបាលភ្លាមបាត់ឈឺបាត់ហើមភ្លាម ។

-បើបានអ៊ឹជួយមើលអ៊ីចឹង ខ្ញុំអរគុណណាស់ ។

សៃយានខីជ្រួញចិញ្ចើម :

- ឯងប្រាប់អញឲ្យត្រង់មកមើល ? ឯងមិនដែលហ៊ានមាត់អង្វរគេមែនឬ ?

- ហ៊ឺ ! បើអ៊ឹព្រមជួយខ្ញុំ, ខ្ញុំមិនបាច់អង្វរទេ , បើអ៊ឹមិនព្រមវិញខ្ញុំអង្វរឥតប្រយោជន៍ទេ

- ម៉េចឯងថា ឥតប្រយោជន៍ ?

- ព្រោះបើអ៊ឹមិនព្យាបាលខ្ញុំពិបាកចិត្តខ្ញុំយំហើយ ។ បើអ៊ឹមិនបេះព្យាបាលអ៊ឹពិបាកចិត្តម្នង

សៃយានខីត្រហឹម:

- ហ៊ឹះ ! យើងមិនបេះពិបាកចិត្តទេ ។ ឥឡូវយប់ហើយសំរាកត្រង់នេះមួយយប់ចុះ ។

កុមារអត់បាយកន្លះថ្ងៃហើយ ឈឺជើងពេកអង្គុយបានមួយសន្ទុះ ក៏ទន់ត្របកភ្នែកលង់លក់ទៅ ។ សៃយានខី ចិត្តអាក្រក់ណាស់គាត់ឡើងដេកលើមែកឈើ ចង់ឲ្យសត្វសាហាវនាំកុមារនេះស៊ីផាប់ ៗ ទៅទីងរាលគាត់ស្រួលខ្លួន ។ ប៉ុន្តែមនុស្សនិងព្រហ្មលិខិតតែងមានបំណងខុសគ្នាជាដរាប ។

សៃយានខីប៉ិនមួយលើកជាពីរលើក ឥតសុំរេចរោះ ។ មួយយប់ទល់ភ្លឺ សូម្បីកូនទន្សាយមួយក៏ឥតមកក្បែរទីនេះផង កុំថាឡើយដល់សត្វសាហាវ ។ គាត់អស់សង្ឃឹមខ្លួនទៀតនឹកថាឲ្យតែទៅដល់ភ្នំម៉ាន ការល្អិតប្រើធ្វើអីស្រួលបំផុត ក៏យើងចាត់ទុកជាបានគោរពពាក្យសម្ដាដែរ ។ បើវាមិនអង្វរយើងត្រូវរកមធ្យោបាយសម្លាប់វាចោលពាល់តែបាន ! ក្មេងតូចមួយប៉ុណ្ណឹងសម្លាប់មិនបានសមជាម្ចាស់ភ្នំម៉ានដែរឬ ?

ព្រឹកឡើងតាចាស់កំណាចនេះដឹកដៃកុមារកំសត់ប្រុងបន្តដំណើរទៅមុខ ។ ក្មេងតូចក្រោកដើរបានបន្តិច , ក៏ស្រែកយ៉ូយៗព្រោះជើងវារិតតែឈឺដូចជាម្ជុលរាប់រយចាក់ឈុកៗ...

សៃយានខីឆកសួរ:

- យ៉ាងម៉េចទៅហើយអាតូច ?

ព្រមទាំងនឹកថា បើឯងអង្វរឲ្យអញសំរាកក៏ទុកជាបានការដែរ ។

តែកុមារបំឡែកនេះពោលផ្សេងវិញ:

– បាតជើងខ្ញុំឈឺដល់ហើយ ! តែមិនអីទេ... ទៅ !

ស៊ៃយានទី ទាល់ចំណោះបែរជាក្តៅក្រហាយខឹងណែនទ្រូង ទាញដៃកុមាររត់លឿនរឹងតទៅទៀត គ្មានឈប់សំរាកតាមផ្លូវឡើយ ។ ពេលណាដើរកាត់ភូមិមានផ្ទះលក់នំចំណី គាត់ឆក់ខ្លះប្រកហោ ចៅ រត់បណ្តើរ ស៊ីបណ្តើរ ចង់ហុចឲ្យក្មេងតូចខ្លះក៏ហុចទៅ...

អ្នកទាំងពីរធ្វើដំណើររបៀបនេះគ្រប់ ៦ ថ្ងៃទើបដល់ព្រៃភ្នំក្រំថ្ម ផ្លូវដើរជុំពិបាករត់ក្រៃលែង តែគួរចម្លែកណាស់ កុមារកំសត់ចាប់អារម្មណ៍ចម្លែកថា វារត់យូរកាន់តែលឿនឡើង ហើយបាតជើងក៏លែងឈឺលែងហើមអស់រលីង ។ គេបន្តដំណើរមួយថ្ងៃទៀតកាន់តែពិបាកឡើងៗ ធ្វើឲ្យកុមារតូចរត់លែងទាន់ ។ ស៊ៃយានទីហាក់ប្រញាប់ណាស់ , គាត់លើកវាលើស្មារត់ឆ្លងថ្ម ឆ្លងជ្រោះជ្រៅបណ្តាលឲ្យកុមារនេះព្រឺក្បាលសំពោង បិទភ្នែកឥតហ៊ានមើល ។

ដល់ពេលថ្ងៃត្រង់ទើបស៊ៃយានទីលីក្មេងតូចនេះដល់ជើងភ្នំមួយខ្ពស់ត្រដឹមរលោងស្រឡិល ។ គាត់ចាប់ប្រវាក់មួយខ្សែដែលធ្លាក់ពីលើមកតោងឡើងទៅលើដូចពានរ ។ បើគ្មានប្រវាក់ស្រាប់ម្ល៉េះ សមគាត់ឡើងមិនរួចទេ ព្រោះភ្នំនេះខ្ពស់ហើយគ្មានកន្លែងឆកសំពប់ដាក់ជើងសោះ ។

ស៊ៃយានទីវារឡើងដល់កំពូលភ្នំ ទើបទម្លាក់កុមារត្រដោលចុះពោលថា :

–នេះគេហៅភ្នំម៉ាធាន ហើយយើងជាម្ចាស់ណា៎ ! ឯងនៅជាមួយយើងសិន ។

កុមារកំសត់ឥតដឹងខ្លួនថាស៊ៃយានទីបានបំណាកកក្រក់ចំពោះខ្លួនឡើយ ។ វាងាកមើលជុំទិស ឃើញវាលធំធេង ពពករសាត់ទាំងដុំៗជិតក្បាល ដូចនៅកណ្តាលអាកាសវេហាស៍,វាភ័យតក់ស្លុតសួរ :

–ក្រែងអ៊ំនាំខ្ញុំទៅរកម៉ែនិងរកវ្លួងឬ ?

–យីក្រោមមេឃលើដីធំម្ល៉េះៗទៅរកឯណាឃើញ ? យើងនៅទីនេះសិន ក្រែងមានថ្ងៃណាមួយ ម្តាយឯងមករកណា៎ !

កុមារនេះក្មេងហើយល្ងង់មែន តែវាមិនល្ងើដល់ជឿពាក្យសំដីបោកប្រាសរបស់ស៊ៃយានទីទេ ព្រោះវាចេះនឹកថាបើម្តាយវារកឃើញភ្នំនេះក៏គ្មានមធ្យោបាយឡើងមកដែរ ។ ម្តាយវាមិនចេះស្រឡាញ់ថ្នាក់ថ្នមកូនមែនតែគាត់មិនដែលកុហកកូនទេ ។ ពេលនេះកុមារធ្វើមុខស្រងូតនិយាយលែងចេញ, ទឹកភ្នែករលីងរលោងតែវាខាំមាត់មិនឲ្យស៊ៃយានទីឃើញឡើយ ។

គាត់សើចកំណាចពោលជាបញ្ចប់ថា :

– កាលណាឯងចង់ចុះក្រោម ឯងប្រាប់អ៊ំណា ?

គាត់នឹកក្នុងចិត្តថា: បើយើងបង្អត់អាហារឯង គង់មានថ្ងៃឯងស្លូតដើរចេញ អង្វរសុំបាយយើងស៊ីមិនខាន ។

តាចាស់ពោលចប់ដើរចូលក្នុងរូងភ្នំបាត់ ។ មិនយូរប៉ុន្មានកុមារក៏សត់ឃើញផ្សែងហុយទ្រលោមចេញមកហើយធុំក្លិនឈ្ងុយឈ្ងប់តាមក្រោយទៀតគឺ សេយានទី បង្កាត់ភ្លើងដណ្តាំបាយបរិភោគ ។

កុមារស្រក់ទឹកមាត់ព្រោកក្រោកក្រេះ សំលៀវរូងភ្នំចូលផ្លូកឃើញកន្ទេងទូលាយល្វឹង បាយសម្លនៅមាត់រូងតែម្តង ព្រោះយានទីដាក់ត្រង់ពេភះឲ្យពេលក្លិនទៅដល់ច្រមុះអាតូចក្រេងវាសុំគាត់ស៊ី ។ តែកញ្ចាស់នេះភ្លេចនឹកថា កុមារក៏សត់ធ្លាប់រស់នៅតែពីរនាក់ម្តាយកូនកណ្តាលព្រៃភ្នំមិនចេះគួរសម មិនស្គាល់សុជីវធម៌អីទេ ។ កាលបើចូលទៅឃើញបាយសម្លនិងចានចង្កឹះនៅពេញលើតុច្នៃ វាផ្លូសបាយចាប់សាច់ទៀតស៊ីព្រាងើយ ។ សេយានទីភាំងខ្លួនមួយសន្ទុះ ទើបនឹកថា:

– ណ្ហើយ ! ឲ្យវាស៊ីម្តងវិញចុះ ព្រោះវាធ្លាប់ឲ្យនំយើងហូបដែរ, កុំអាលរមិលគុណវា ។

កុមារនេះធ្លាប់បរិភោគបាយទល់មុខម្តាយ ឥតនិយាយស្តីតាំងពីតូចមក ម្ល៉ោះហើយវាទទួលទានរួចភ្លាម លើកចានចង្កឹះនិងឆ្នាំងទៅដុសលាងស្អាតទុកដាក់អស់ ទើបចេញទៅកាប់អុស ។ ពេលប្រមូលអុសមករូងភ្នំវិញ ស្រាប់តែឮសូរទ្រហ៊ក គឺទន្សាយមួយលោតផ្លោតពីគុម្ពស្មៅមក, កុមារយារឮហៅកាប់ផូងស្លាប់ស្លក ។ វាពើសទៅពន្ទាត់ស្បែក វះពោះលាងទឹកជ្រោះស្អាតបាតទើបកងអុសត្រឡប់ទៅរូងភ្នំវិញ ។ វាធ្វើដូចធ្លាប់នៅជាមួយម្តាយ គឺយកសាច់ទន្សាយមួយចំហៀងប្រឡាក់ទុកហាលធ្វើងៀតមួយចំហៀងទៀតស្ងួ ។

មិនយូរប៉ុន្មានសេយានទីធុំក្លិនសម្លឈ្ងុយឆ្ងាញ់ពេញរូងក៏ស្ទុះទៅរកវែកជួសសម្លទន្សាយភ្លក្ស លាន់ផឹប ៗ ព្រោះកុមារចម្លែកនេះចេះស្លឆ្ងាញ់លើសគាត់ឆ្ងាយណាស់ ។ តាចាស់ក៏ហួចក្រេកអរផងគប់ប្រមល់ផង នឹកថា :

– យើងមិនដឹងអាស្អិតនេះចេះធ្វើម្ហូបកៅយ៉ាងចំណានដូច្នេះសោះ ! តែប៉ុណ្ណេះបានឆ្ងាញ់មាត់ហើយ ! យី ! ... បើវាប្រុសប៉ុម្នឹង ១ វាមិនអង្វរយើងសុំចុះទៅក្រោមវិញទេ , យើងក៏មិនដឹងធ្វើអីវាដែរ .. ពិបាកណាស់ហ្ន៎ !

ក្បែតកូននេះធ្លាប់នៅជាមួយម្តាយជាអ្នកចេះធ្វើម្ហូបចំណានណាស់ ។ ប៉ុន្តែគាត់មួម៉ៅច្រើន

ហើយខ្ជិលផង ក៏ចេះតែប្រើកូនតូចឲ្យធាំស្លធំនួសគាត់ កាលណាគាត់សប្បាយចិត្ត គាត់ជួយប្រាប់ជួយបង្រៀន ពោលតែគាត់មិនសប្បាយចិត្តស្ដីបន្ទោសកូនឬវាយវាត់ឥតត្រាប្រណី ។

ផល្លាវកុមារនៅលើភ្នំម៉ោនឧស្សាហ៍ណាស់ វាធ្វើអន្ទាក់និងសំណាញ់ចាប់សត្វគ្រប់ជុន ស្លថ្ងៃតែចរចេកជាមួយសើយានទី កាលណាស្លបិនអស់វាប្រឡាក់អំបិលហាលទៀត ។ យានទីសប្បាយចិត្តហើយឆ្ងល់ណាស់ មិនគួរក្មេងប៉ុណ្ណឹងចេះធ្វើម្ហូបអាហារថ្លៃកាហើយឆ្ងាញ់ថ្លៃខ្ទេះសោះ ។ ដល់សួរវា វាថាចេះពីម្ដាយ ។

គាត់ពិចារណាថាម្ដាយវាចេះធ្វើម្ហូបឆ្ងាញ់ៗមែន អ្នកស្រីពិតជាមានពូជអម្បូរនឹងគេដែរតែត្រូវស្លាប់តែពេលបានជាមួយមៅក្ដៅក្រហាយមិនលោះពេលហើយមិនចេះស្រឡាញ់ថ្នាក់ថ្នមកូន, ឬមួយគាត់គាបពីដំបូងទាល់តែប្ដីត្រាំមិនបានដោះដៃពេលទៅ ?

ថៃសើយានទីពិបាកតែម្យ៉ាងត្រង់ក្មេងនេះមិនចេះនិយាយស្ដី មួយថ្ងៃៗគិតតែធ្វើការជួបវានៅជាមួយម្ដាយវា ម្ល៉ោះហើយគាត់បារម្ភណាស់ មិនដឹងធ្វើយ៉ាងណាឲ្យសំរេចដូចបំណងធាប់ៗក្នុងការគោរពពាក្យសំបថ ។ គាត់ភ័យម្យ៉ាងទៀតខ្លាចមានអ្នកក្លាហានឯណាមកដល់ទីនេះបញ្ឆោតគាតួបឲ្យអន្ទរគាត់កាត់ដៃជើងឬរំលាយយុទ្ធសិល្បៈខ្លួនឯងពេលឬម៉្យាងទៀត មិនឲ្យគាត់ចាកចេញពីភ្នំម៉ោនហ្មួតមួយជីវិត ។ គាត់សុំទុបក្បាលជង្គង់សញ្ជឹងគិតទាំងយប់ទាំងថ្ងៃ មិនដឹងដោះស្រាយរឿងនេះតាមមធ្យោបាយណា . . .

ពេលថ្ងៃត្រង់ហូបបាយរួច សើយានទីក្រពាត់ដៃត្រិះរិះក្នុងព្រៃ ក្រឡេកឃើញកុមារកំសត់អង្គុយក្បែរដុំថ្មមួយពោនស្រិល សង្កេតវត្ថុអ្វីល្អិតៗ ដោយទឹកមុខញញឹម ។ គាត់ដើរទៅជិតលោកមើលទើបស្គាល់កូនតក្កតា គាតែតាំង ១៨ ។ ក្មេងតូចរៀបតក្កតាលេងតាមរបៀបក្មេង ម្ដងឲ្យវាតំរៀបជួរដើរតាមទាហាន, ម្ដងរុញច្រានឲ្យប្រយុទ្ធគ្នា, ចំបាប់គ្នា...

វសើយានទីមើលមែនទែន ឃើញចំណុចខ្មៅតាមកន្លែងជីពចរលើខ្លួនមនុស្សសរសៃក្រហាម ១ ជាសរសៃឈាមតំនឹកដល់កាលជួបតាតែលើកដំបូង លើភ្នំតែម៉ាង ។

កាលណោះតាតែចេះគុនដៃទទេពូកែណាស់ ហើយចាប់ខ្ញុំរហ័សលេខមួយ ប្រយុទ្ធគ្នាមួយម៉ោងទើបគាត់ចាញ់តាតែកន្ទុះស្មៀត ។ គាត់ជណ្ដឹងសួរ តើរូបនេះសំរាប់ហាត់រៀនវិជ្ជាអី ?

សើយានទីអង្គុយពោងពោងចាប់តក្កតាមួយមកពិនិត្យឃើញច្បាស់ថា ចំណុចខ្មៅ ១ ជាជីពចរ

មែន ឯសរសៃក្រហមៗ ក៏ជាសរសៃឈាមដែរ ។ មើលចុះមើលឡើងគ្មានឃើញអ្វីចំឡែកសោះ ព្រោះជាចំណុច និង គំនូសដ៏ត្រឹមត្រូវសម្រាប់ហាត់រៀនបំរើនកម្លាំងលើកដំបូង ទោះអ្នកក្លាហានរូបណាក៏ចេះដែរ ។

តាពៃហាត់ពូកែដល់ថ្នាក់ឈ្នះគាត់ទៅហើយ មានត្រូវការរូបតុក្កតានេះធ្វើអីទៀត ? បើជាគាត់ដាក់ប្រអប់ទុកគំរៀបលេងដូចអាតូចនេះ ក៏រឹតតែលែងសមទៀត !

គិតចុះគិតឡើង សៃយានទីទុករូបតុក្កតាវិញផ្ទុះសំណើចក្អាកក្អាយ ។ ក្មេងតូចតំសើចដែរ :

– អ៊ំមើលនែ , កូនតុក្កតាអស់នេះសុទ្ធតែមានពុកមាត់ , មិនមែនក្មេងទេ ម៉េចគេមិនស្លៀកខោពាក់អាវឲ្យវាផង ? ចង់សើចណាស់ហ្ន៎អ៊ំ ?

– អើគួរសើចមែន !

សៃយានទីពោលតែប៉ុណ្ណោះ នឹកស្រមៃដល់ឆាកប្រយុទ្ធលើក្ដៃពមាំងទៀត :

–កញ្ចាស់តាពៃចង់ចេះរបៀបបំរើនកម្លាំងធាតុ ម៉េចមិនរកសិស្សគណខាងក្រុមណាមួយបង្ហាត់បង្ហាញ? ចំណាស់ហ្នឹងចេះយុទ្ធសិល្បៈប៉ុណ្ណឹង ស្ដាប់គេពន្យល់តែបីថ្ងៃចេះស្ទាត់ស្រេច ! ស្អីមែន! កញ្ចាស់នេះវាយប្ញុកធំមិនបន្ទោកខ្លួនហៅរកក្មេងក្មេងបង្ហាត់បង្រៀនទេ ! ហាស់ៗ . . . គួរអស់សំណើចទៀតហើយ . . . កាលប្រយុទ្ធគ្នាលើកនេះយើងឈ្នះកន្ទុះស្លៀក ដោយចៃដន្យទេព្រោះក្នុងរយៈពេលជាង ១ម៉ោងនោះយើងភ្ញាក់ស្លៀកម្ដងៗ ព្រលឹងទៅចុងសក់ដែរ ។

អីយ៉ា ! ( សៃយានទីព្រឺក្បាល ) កាលណោះតាពៃឥតចេះវិធីបម្រើនកម្លាំងធាតុទេតើ កុំអីយើងចាញ់គាត់យូរណាស់ហើយ ។ បែបត្រូវកញ្ចាស់នោះទះមៀលពីលើខ្នងក្នុងផង ក៏មិនដឹង ។ ហ៊ុះ ! ឥឡូវគាត់ស្លាប់មុនយើងហើយ ...

សៃយានទីហៀបបោះជំហានដើរចេញទទួល នឹកឃើញរឿងមួយក៏ឈប់ងឹកសួរកុមារតំសត់

– អាខាង ! ឯងដឹងថាគំនូសក្រហមនិងចំណុចខ្មៅលើខ្លួនតុក្កតានេះជាអ្វីដែរ ?

– កូនមនុស្សនេះឈឺហើយអ៊ំ ។

–យី! ម៉េចឯងថាឈឺ ?

–កាលមុនខ្ញុំមានកើតអុចៗ ខ្មៅអ៊ីចឹងដែរ, ម៉ែខ្ញុំថាខ្ញុំឈឺ . . .

សៃយានទីអស់សំណើច :

-យី កូននេះល្ងង់មែន ! មិនអីទេ កាលពីយើងបង្ហាត់ឲ្យឯងបេះចំរើនកម្លាំងជាតុ តាមទ្រឹស្តីបោកប្រាស់ម្តង ! ហ៊ុះ ! យើងឥតសច្ចាថាមិនត្រូវបង្ហាត់បង្រៀនឯងខុសរបៀបទេ ហេតុនេះត្រូវបង្រៀនឯង ហាត់ខុសទ្រឹស្តីឲ្យកម្លាំងឯងរត់ប្រាសផាច់ខ្យល់ស្លាប់តាយ ហោងលើក្នុះយើងចុះ កុំនៅអំពល់ទុក្ខយូរពេក ។

សៃយានទឹកាន់ពាក្យសច្ចៈ តែមិនបេះការណ៍គេមេត្តាករុណាគេទេ, ស្គាល់តែប្រយោជន៍និងសេចក្តីសុខផ្ទាល់ ។ កាលបើសម្រេចចិត្តដូច្នេះហើយ គាត់សើចហាសៗ :

– កាលឯងឈឺនេះគេហៅថា កើតអុត, រីចំណុចខ្មៅនេះជារបៀបហាត់រៀនគុនវិជ្ជាណា ! ឯងឃើញអីកៀបឯងរត់លឿនដូចគេហោះទេ ? អីពូកែឬ មិនពូកែ និយាយមកមើល ?

ពោលផងទន្ទ្រាំជើងលោតវឹងផុតដីជ្រុងលើមែកស្រល់សើចហាសៗរួចហក់មួយវឹបទៀត ជាន់មែកខាងលើផ្លោតទៅដល់ចុងរួចទើបទម្លាក់ខ្លួនសន្សឹមៗមកដីវិញ ។ ពេលនោះមានចាបពីរហើរកាត់មុខគាត់, គាត់ចាប់ចាបទាំងពីរក្តោបផាប់ឲ្យក្មេងតូចកោត ។ មែន ! កុមារកំសត់ទះដៃស្រែកហោ :

– ពូកែមែន ! ពូកែមែន !

សៃយានទីលាបាតដៃឲ្យចាបទាំងពីរទះស្លាបហើរកើល តែគាត់បញ្ចោកម្លាំងកាយរំលាយសន្ទុះបក្សាភ្លាម ចាបទាំងពីរហើរមិនផុតបាតដៃគាត់សោះ ។ កុមារមិនដឹងខ្យល់អីរតែសប្បាយលើសដើម ទះដៃស្រែក :

– សប្បាយណាស់, សប្បាយមែនអី !

សៃយានទីសើចទឹកពោល :

– ឥឡូវឯងសាកម្តងមើល !

ពោលហើយ គាត់ដាក់ចាបទាំងពីរលើដៃអាតូចៗ ទំក្តាប់ផ្ទាប់ឥតហ៊ានលែង ។ យានទីពន្យល់:

-ចំណុចខ្មៅៗ លើកូនតក្កតានេះជារបៀបហាត់រៀនឲ្យពូកែដូចអីអ៊ីចឹង ។ ឯងមិនស្គាល់ជីវិតហ៊ានចេញមុខជួយតាចាស់នោះបានជាគាត់ឲ្យប្រូតក្កតាអស់នេះជារង្វាន់ ។ មិនមែនល្បែងជម្ពូតាទេ, គឺជាវត្ថុថ្លៃថ្លា មានប្រយោជន៍ចំពោះឯងណាស់ ដឹងទេ ? ដល់ឯងចំហាត់រៀនចេះស្ទាត់, ឯងពេចលាដៃដូចអីឥតឲ្យសត្វចាបហើរ ទៅណាបានទេ ។

កុមារកោតណាស់ :

-ខ្ញុំចង់ធ្វើដូចអ៊ីដែរ, តែត្រូវហាត់យ៉ាងម៉េចទៅ ?

ពេលហើយវាលាដៃបើកផ្លូវឲ្យសត្វតាបទទះស្លាបហើរកិលបាត់ទៅ ព្រោះវាមិនបេះបញ្ចេញកម្លាំងទប់សន្ទុះបក្សា ។ សើយានទីក្ដាយសំណើចក្អាកក្អាយលើកដៃឡើង ស្រាប់តែសត្វតាបដដែលធ្លាក់ខ្ទាកលើដៃ កុមារបំប្លែកស្លាប់ស្ងួក ។ យានទីធ្វើភ្នែកក្រឡង់ភ័យតក់ស្លុត ឈប់សើចភ្លាមហើយរុញដៃម្ខាង ចុចដីពបរកុមារជាប់ ដៃម្ខាងទៀតយារទះកណ្ដាលថ្ងាសវាគំហកសួរ :

-ឯងជាសិស្ស . . .សិស្សកញ្ចាស់ . . . ទីងមិនហួសប្អូនឬ? ប្រាប់ឆាប់មក!

សើយានទីធ្លាប់លុកលុយពិភពគុនយូរឆ្នាំហើយ តែគាត់នៅញញើតឈ្មោះទីងមិនហួសប្អូនដដែល ពេលឈ្មោះទីងម្ដងណាក៏ភ័យញាប់ញ័រដែរ ។ ទីងមិនហួសប្អូនត្រូវជាបងប្អូនទីងមិនហួសបីតែគេមានវិជ្ជាប្រឋាំកាយម៉្យាងពូកែចំឡែកណាស់ហៅថា«ធាតុគ្រជាក់ដៃទន់» ។ ពេលនេះឃើញក្មេងតូចក្ដាប់តាបស្លាប់មួយពាន់ហាន់គ្រជាក់ស្រិបភ្លាបក៏យល់ថាកេតូចនេះ ហាត់រៀនពីទីងមិនហួសប្អូនច្រើនឆ្នាំហើយ ទើបសំដែងបានលទ្ធផលគាប់ប្រសើរបបនេះ ។

យានទីយល់ម៉្យាងទៀតថា អាតូចជាសិស្សជំនិតដែលទីងមិនហួសប្អូនប្រើឲ្យយកបញ្ជាដែកសិរីខ្ញុំមកលួចផ្ទៀតវង់ចាំឱកាសល្អ ដើម្បីបញ្ចេញសំណូបពរតាមកិច្ចសន្យា, ព្រោះហេតុហ្នឹងហើយបានជាអាតូចមិនព្រមសុំអង្វរអ្វីសោះ ។ ឌុ! ការនេះលាក់ពុតទេតើ! វារង់ចាំពេលវេលាល្អដើម្បីបញ្ជា ឬមួយកញ្ចាស់ទីងមកដល់ភ្នំម៉ានដែរ ?

សើយានទីផ្លាស់ប្ដូរទឹកមុខម្ដងស្លាំង, ម្ដងក្រហម ភ្នែកពាក់ក្រឡាប់មើលគ្រប់ទិសសង្ស័យ ក្រែងទីងមិនហួសប្អូនលបមើលពីកៀនកោះណាមក ។ គាត់ឈរធ្មឹងនឹកភ័យម៉្យាងទៀតថា :

- ប៉ុន្មានថ្ងៃនេះ យើងស៊ីបាយសម្លអាតូចមិនដឹង តើវាដាក់ថ្នាំពុលឬទេហ្ន៎ ? បើទីងមិនហួសប្អូនចង់សម្លាប់យើង, គិតធ្វើម៉េចទៅ ? ដល់អាតូចនេះបេញបញ្ជា តើវាប្រើយើងឲ្យធ្វើអី ? យីពិបាកមែនតើ !

ចំណែកអាតូចកំពុងភ័យស្រែកស្ងួន :

- អ៊ឺ . . . អ៊ឺ ! ឈឺណាស់ ! ស៊ូ ! ទីងមិនហួសប្អូនមកពីណាខ្ញុំមិនស្គាល់ទេ ។

សើយានទីអាល័យតែបារម្ភនឹកស្រមៃទៅឆ្ងាយមិនបានជាគិតទើបតាប់ប្រួបាច់ដៃវាខ្លាំងឡើងៗវាឈឺ

ស្រែកញាប់មាត់នេះឯង ។ ពេលនេះគាត់ភ្ញាក់ស្មារតីនឹកថា បើទីងមិនហ្លួសប្អូនលបមើលយើងក្បែរៗនេះដែរ យើងមិនត្រូវធ្វើបាបវាទេ ម៉្លោះហើយគាត់លែងដៃវាចេញហើយស្រែកខ្លាំងៗ ៖

– កូនម៉ាន របស់យើង តិចមានអ្នកក្លាហានណាមកដល់ណាស់, បើទីងមិនហ្លួសប្អូននៅលើភ្នំនេះដែរ សូមប្រញាប់បង្ហាញរូបមក !

សែ យានទី ស្រែកពីរបីដង ពុំតែសម្លេងរំពងមកវិញខ្ទរខ្ទាថា បង្ហាញរូបមក !... បង្ហាញរូបមក ! មួយសន្ទុះធំមិនឃើញស្រមោលអ្វីសោះទេ៎ប យានទី ទន់រើសតាមចាំងពីរដែលស្ទាប់រឹងក្រញង់ក្រដាក់ស្រេបមក ប្របាច់ព្រុប្រ៊ុបយ៉ាងស្រាល ។ គាត់ធ្វើនេះដើម្បីចង់ដឹងច្បាស់តើអាតូចបេះស្នៀតធាតុត្រជាក់ដែលទន់ដល់កំរិតណា ?

លុះប្របាច់ព្រុប្រ៊ុបគាត់យល់ច្បាស់ថាវាបេះត្រឹមបីបួនភាគ ហើយបានជាឈាមបាប៉ុកក្នុងខ្លួនអស់ក្នុងពេលយ៉ាងខ្លី ។ ប្រសិនបើទីងមិនហ្លួសប្អូនប្រញាប់ផ្ដាស់ដៃវិញ ចាបចាំងពីរអាចក្លាយជាទឹកកកពីរដុំបាន ដោយអំណាចធាតុត្រជាក់ជ្រៀតចូលក្នុងគ្រឿងប្រដាប់និងសាច់ឈាមខ្លាំងពេក ។ យានទីព្រឺក្បាលសំពោងនឹកបារម្ភណាស់ រៀបចំទឹកមុខពោលល្បួងលោមអាតូច ៖

– អានាងក្លា ! អំដឹងគោលបំណងឯងហើយ កុំធ្វើពើដល់ណាទៀត ។ ប្រាប់អំមកមើល ទីងមិនហ្លួនប្អូនត្រូវជាអីនឹងឯង ?

– ស្អីហៅទីងមិនហ្លួសប្អូន ? ខ្ញុំឥតស្គាល់ទេ ។

– ល្អ ! បើឯងមិនប្រាប់ទេ ឯងដេរទីងមិនហ្លួសប្អូនមួយម៉ាត់ឲ្យអំស្ដាប់ផងមើល ?

– យីអំ ! អំប្រាប់ខ្ញុំថាមិនត្រូវដេរគេ ម៉េចថ្ងៃនេះអំឲ្យខ្ញុំដេរទីងមិនហ្លួសប្អូនដែលឥតមានធ្វើអ្វីនឹងខ្ញុំផង ? ខ្ញុំមិនស្គាល់ផងដេរគេម៉េចរួច ?

សែ យានទីឃើញកុមារធ្វើមុខស្លុតយល់ខុសថា អាតូចមិនហ៊ានដេរគ្រូវាមែន ហ៊ឺយើងលើកដៃទះឯងសម្លាប់នឹងកន្លែងបានណា ! ទោះទីងមិនហ្លួសប្អូនខ្លាំងពូកែយ៉ាងណាក៏គេមកជួយមិនទាន់ដែរ ។ ព្រោះនោះគាត់នឹកឃើញម្យ៉ាងទៀតថាទីងមិនហ្លួសប្អូនទុកចិត្តយើងថា យើងមិនហ៊ានរំលោភពិចូសន្យាបានជាហ៊ានបណ្ដោយអាតូចនេះឡើងភ្នំជាមួយយើង ។ ដូច្នេះមិនត្រូវធ្វើបាបវាទេ ។

សែ យានទីនិងទីងមិនហ្លួសប្អូនមិនដែលស្គាល់មុខគ្នា ហើយឥតមានគំនុំអ្វីទេ គ្រាន់តែធ្លាប់ព្រឺឈ្មោះគ្នាទៅវិញទៅមក ។ សែ យានទីភ័យបុកពោះដោយគាត់យល់ថាអាតូចជាសិស្សទីងមិនហ្លួសប្អូន ថា

គាត់ទាញឧបាយកលចិន ។ គាត់សួរថា :

– អានានក្ហា ! វិជ្ជាធាតុត្រជាក់ដៃទន់ឯងពូកែណាស់ , ឯងរៀនប៉ុន្មានឆ្នាំហើយ ?

– យ៉ីអ៊ីថ្ងៃនេះបែបមិនស្រួលខ្លួនឬ ? វិជ្ជាអីនោះខ្ញុំមិនចេះទេ... ម៉េចអ៊ីសួរខ្ញុំប្លែក ៗ ម៉្លេះថ្ងៃនេះ?

– យីអើ ! យើងសួរឯងម្តងណា ក៏ឆ្លើយមិនដឹង ៗ ... ឯងមើលងាយមើលថោកយើងម៉្លេះ ?

កុមារគ្រវីក្បាលដោយឥតយល់អ្វីសោះថា :

– អ៊ីកុំខឹងអី , ខ្ញុំល្ងង់ណាស់ធ្វើឲ្យអ៊ីខឹង ... អូ ! នឹកឃើញហើយ ខ្ញុំសម្លាប់សត្វចាបអស់ពីរនេះឬ ? អ៊ីគ្រាន់តែហោះដូចអម្បាញ់មិញចាប់បានទៀតហើយ , តោងហោះចាប់ពីរមកទៀតបង្រៀនខ្ញុំផង ធ្វើយ៉ាងម៉េចកុំឲ្យវាហើររួច ?

សៀយានទីគិតមួយសន្ទុះ ទើបឆ្លើយ :

– បាន ! ចាំយើងបង្ហាត់ឯងឲ្យចេះស្ទាត់ ។

បន្ទាប់មកគាត់ចាប់គក្កតាមួយបង្អុលប្រាប់កន្លែងខ្សៅ ១ :

– នេះគេហៅជីពចរ ស្រួលរៀនជាងវិជ្ជាធាតុត្រជាក់ដៃទន់ឆ្ងាយណាស់ ។ ឯងស្តាប់ឲ្យច្បាស់ហើយចាំរៀនទៅពីរបីថ្ងៃចេះដូចអ៊ីហើយ ។

គាត់សូត្រទ្រឹស្តីបំពេញកម្លាំងក្តៅយ៉ាងក្បោះក្បាយឲ្យអាតូចស្តាប់ ។ កុមារនេះបែបឆ្លាតហើយចេះវិជ្ជាធាតុត្រជាក់ផង តែពេលនេះវាមិនស្គាល់ជីពចរហើយមិនចេះដកដង្ហើមត្រឹមត្រូវតាមរបៀបទេ ។ សៀយានទីប៉ងបង្ហាត់ធាតុក្តៅ ដើម្បីរំលាយធាតុត្រជាក់អស់ពីខ្លួនវាផងឲ្យកម្លាំងធាតុទាំងពីរប្រឆាំងគ្នាផង ។ ប៉ុន្តែការនេះមិនសំរេចភ្លាម ១ បានក៏ដូចជាអាតូចមិនងាយស្ទាប់ដែរ គោងខំបង្រៀនវាកប់ឆ្នាំទើបប្រមូលធាតុក្តៅបានស្មើធាតុត្រជាក់ ។

កាលបើឃើញកុមារនេះលួងសត្វគ្រប់ខាងវិស័យគុន, សៀយានទីខឹងឆេះឆួលនឹកថា :

– ឲ្យឯងធ្វើពើទៀតសិនចុះ ! ចាំមើលតែហាត់ដល់កំរិតឯងស្គាល់ស្នាដៃយើងហើយ ។

សៀយានទីនឹកឃើញយ៉ាងនេះទើបខំអត់ទ្រាំបង្ហាត់បង្រៀនក្មេងកំសត់រហូតចេះ ចប់សព្វគ្រប់តាំងពីរបៀបដកដង្ហើមបន្ទរបន្ទយខ្យល់ ។ល ។ កុមារកំសត់នេះខំរៀនមែនទែនហើយខំបញ្ចេញសត្វដាំបាយកាប់ឧសបំរើសៀយានទីឥតខ្ចោះ គ្មានចាប់ភ្ញាក់ឬសង្ស័យថាតាចាស់នេះ ចង់បំផ្លាញជីវិតខ្លួនសោះទេ ។ ចំណែកតាចាស់ចិត្តអាក្រក់ក៏បានស្រាវប្រាវកមកទុកវិញ តាំងពីខ្វាចទីងមិនហួស

ប្អូនមកគេរឿងគាត់ដែរ ។

រដូវមួយកន្លងទៅ រដូវមួយទៀតចូលមកដល់... បន្ទាប់ពីរដូវវស្សាដល់ហើយដើមឆ្នាំ គ្មានឃើញស្រមោលមនុស្សមកក្បែរ ភ្នំប៉ានផង កុំថាដល់ហ៊ានឡើងភ្នំលោងស្រិលនេះ ។

សៃយានទី ឃើញអង្ករនិងអំបិលជិតអស់ហើយ គិតថាត្រូវចុះហាកភ្នំរកទិញមកទុក ក្នុងរូងភ្នំដើម្បីចិញ្ចឹមជីវិត តទៅទៀត ។

តែគាត់ពុំទុកឲ្យកុមារនៅម្នាក់ឯងទេ ព្រោះបើនរណាលបឡើងមកចាប់ក្មេងនេះបាន នោះជីវិតគាត់ក៏នឹងធ្លាក់ទៅក្នុងកណ្ដាប់ដៃគេដែរ ។ គាត់នាំកុមារចុះពីភ្នំដោយប្រុងប្រយ័ត្នក្រៃលែង ហើយបន្ទាប់ពីទិញអង្ករនិងរបស់របរផ្សេង ៗ ស្រេចបាច់ហើយ ក៏វិលមកភ្នំវិញភ្លាម ។ តាំងពីប្រាណរស់នៅលើភ្នំកប់ខ្មោចក៏សុខសាន្ត ហើយមួយឆ្នាំម្ដង ៗ តែងចុះមករកស្បៀងជានិច្ច ។ ភ្លេចភ្លើក ។ មាណពអាយុ ១៨ឆ្នាំស្រេច នាយហានរូបកាយស្អាតបាតមាំមួននិងខ្ពស់ជាងសៃយានទីទៅទៀត ។

សៃយានទី នៅតែមានមន្ទិលបន្តិចដែរ ពេលយប់គាត់មិនដេកក្នុងរូងភ្នំជាមួយមាណពទេ ហើយកាលពេលបរិភោគគាត់តែងចាំឲ្យនាយភក្សមុន ទើបហ៊ានស្រស់ស្រូបជាក្រោយ ។ ក្រៅពីពេលបង្ហាត់បង្រៀនយុទ្ធសិល្បៈ គាត់ពុំសូវនិយាយលេងជាមួយមាណពទេ តែការគប្បកិរិយាសោះអង្គើយនេះពុំបានធ្វើឲ្យនាយហានអាក់អន់ចិត្តអ្វីទេ ព្រោះពីតូចកាលនៅលើភ្នំជាមួយម្ដាយ នាយស៊ាំនឹងភាពសោះកក្រោះព្រងើយកន្តើយនិងការយំយែររបស់ម្ដាយអស់ទៅហើយ ។ ជីវភាពលើកំពូលភ្នំស្ងាត់ជ្រងំ ធ្វើឲ្យស្រងេះស្រងោចព្រោះពាការស្រណោកពេកក្រៃ...

ក្រៅពីពេលបរបាញ់,មាណពតែងរំហាត់រៀនគតបានច្រើន ។ ប៉ុន្មានឆ្នាំកន្លងទៅនេះវិជ្ជា«ក្ដៅឧណ្ហៗ»របស់នាយបានល្អគួរលាស់គួរជាទីពេញចិត្ត ។ ចំណែកសៃយានទី រៀងរាល់ទិវារាត្រី គាត់ខំហ្វឹកហ្វឺនផុសទាត់គម្រិះផ្តាល់និងស្រាវជ្រាវវិជ្ជាផ្សេងៗ សម្រាប់ទប់ទល់ធាតុត្រជាក់ឥតមានល្ហែ ព្រោះគាត់បារម្ភខ្លាចពពួកអ្នកក្លាហានដូចជា«ទឹងមិនហួសប្អូន»ជាដើម លបវាយឆ្លក់នៅថ្ងៃណាមួយ ។

ព្រឹកព្រលឹម ខ្យល់ភ្នំជាយជាតិរងើយ ។ សៃយានទី កំពុងដើរលំហែកាយ យ៉ាងរីករាយ ស្រាប់តែប្រទះមាណពអង្គុយតែនក្ដែនលើថ្មដុំមួយ បែរមុខទៅទិសខាងកើត ។ មិនយូរប៉ុន្មាន ផ្សែងសស្តើង ៗ សាយភាយចេញពីក្បាលនាយ , នេះជាសញ្ញាសម្រេចផលនៃវិជ្ជាកម្លាំងធាតុ ។

ម្ចាស់ភ្នំម៉ានានឃើញដូច្នេះញញឹមក្នុងចិត្ត : « កានានឯង ជើងមួយឈានចូលក្នុងឋាននរកហើយ » ហើយប្រញាប់បោះពួយសំពៅព្រៃធំមួយខាងក្រោយភ្នំទាំងក្ដីសប្បាយ ។

ក្នុងព្រៃធាតុអាកាសត្រជាក់ស្រួលខ្លួនណាស់ គាត់ស្រូបខ្យល់ពេញសួតហើយ ត្រវីត្រវាត់ដៃ ទះគប់ដើមឈើធំ ១ ដោយកាយវិការរហ័សរហួនក្រៃលែង ។ ស្លឹកឈើធ្លាក់រពុយដូចគ្រាប់ភ្លៀង តែគាត់បញ្ចេញស្នៀតវាយទប់មិនឲ្យស្លឹកទាំងនេះធ្លាក់ដល់ដីឡើយ ។ ដោយសារកម្លាំងខ្យល់ខ្លាំងក្លា ស្លឹកឈើប្រែក្លាយទៅជាចំរៀកសំពត់ពណ៌ខៀវ ហ៊ុមព័ទ្ធខ្លួនគាត់ជុំជិត មើលទៅគួរស្ញែង !

ក្នុងរយៈប៉ុន្មានឆ្នាំនេះ គាត់មានការជឿនលឿនច្រើនណាស់ ម៉្លោះហើយគាត់អាចបញ្ចេញកម្លាំងធាតុតាមបំណងដើម្បីពតឲ្យកាន់តែធំ ១ ទៅ ។ វាយវាត់យូរទៅកាន់តែរហ័សរហួនឡើង កាន់តែស្រួលខ្លួនឡើង ! គាត់ត្រេកអរនឹងជោគជ័យដ៏ត្រចះត្រចង់រហូតភ្លេចអ្វី ១ ទាំងអស់ ! គាត់ស្លុងគំនិត, គិតតែចំបង្កើនកម្លាំងធាតុមួយមុខប៉ុណ្ណោះ ។ មួយសន្ទុះក្រោយ គាត់បន្ធូរដៃបន្តិចម្ដង ១ លុះត្រាតែស្លឹកឈើធ្លាក់បន្តបន្ទាប់គ្នាលើដី បង្កើតជាព្រំដ៏ប្រណីតពណ៌ខៀវក្រាលជុំវិញខ្លួន ។

គាត់ផ្ទុះសំណើចក្អាកក្អាយ ស្រាប់តែភ្ញាក់ព្រើតហើយថ្ងោះទឹកមុខមួយរំពេច ព្រោះមនុស្សប្រាំបួននាក់ឈរព័ទ្ធគាត់ពុំដឹងពីអង្កាល់ ។ ជនទាំង ៩ កាន់អាវុធគ្រប់ដៃ,សម្លឹងគាត់យ៉ាងស្ងៀមស្ងាត់ ។ តាមកំរិតយុទ្ធសិល្បៈរបស់សេយានទី ពុំថាឡើយនរណាដើរមកជិត សូម្បីអ្នកនោះនៅឆ្ងាយរាប់យោជន៍ក៏គាត់អាចស្ដាប់ដឹងដែរ ។ តែអម្បាញ់មិញដោយរវល់ជាប់ចិត្តជិតអារម្មណ៍នឹងវិជ្ជាកម្លាំងធាតុទើបពុំបានចាប់ភ្លឹកនឹកនាអ្វីទាំងអស់ ម៉្លោះហើយក៏ពុំថាឡើយត្រឹមជនទាំង ៩ ចូលមកហ៊ុមព័ទ្ធ ទោះបីកក្រើកដីស្រុតបាក់ក៏គាត់មិនដឹងដែរ ។

គាត់យល់ថា អ្នកដែលឡើងមកដល់កំពូលភ្នំម៉ានានមិនដែលមានបំណងល្អចំពោះគាត់ទេ តែលុះមកនឹកឃើញថាសត្រូវមានគ្នា ៩ នាក់ក៏ផ្លូវច្រួងខ្សាកទៅវិញ ព្រោះបណ្ដាអ្នកគុននិយមទាំងអស់គាត់ញញើតតែ « ទីងមិនហួសបួន » ម្នាក់ប៉ុណ្ណោះ ។ « ទីងមិនហួសបួន » និង « ទីងមិនហួសបី » ជាបងប្អូនមែន តែមិនសូវត្រូវរ៉ូវគ្នាទេ ហើយនិយមធ្វើដំណើរតែឯកឯង មិនរួបរួមជាមួយនរណាឡើយ ។ ដូច្នេះពួកទាំង៩នេះប្រាកដជាពុំមែនគឺគ្នា«ទីងមិនហួសបួន» ទេ ។ គាត់ពិនិត្យជនទាំងនោះឃើញមានជនសំគម, អ្នកសក់ខ្ចី និង ជនមុខអាក្រក់ខាងក្រុមឈានល្បី ដែលបានវាយ

លុកម្ចាស់កោះត្រីថ្លាមកាលពីប៉ុន្មានឆ្នាំមុន ។ គាត់ដណ្ដឹងសួរខ្លួនឯង :

– ពួកឈានល្បួឡើងមកទីនេះមានបំណងយ៉ាងណា ? គេចង់ប្រើកម្លាំងបាយបង្ខិតបង្ខំយើងឲ្យចូលក្រុមបក្សគេ ដូចតាតែទេដឹង ?

សេរីយានទីធ្លាប់ស្គាល់ថ្វីដៃអ្នកទាំង៤អស់ហើយ ។ កាលពីដើមគាត់អាចវាយឈ្នះបានស្មើដៃជនទាំង៤ប៉ុណ្ណោះតែឥឡូវគាត់គ្មានព្រឺសោះទេ ។ ទោះជាយ៉ាងនេះក៏គាត់នៅបារម្ភចំពោះជន៦នាក់ទៀតដែរ ព្រោះពុំដឹងគេមានកំរិតយុទ្ធសិល្បៈខ្ពស់ដល់ណា ។ អ្នកទាំង៦មានអាយុម្នាក់ៗប្រហែលសែសិបឆ្នាំ ដោយក្នុងចំណោមពួកនេះមានពីរនាក់ហាក់មានថាមពលស្ដុកស្ដម្ភណាស់ ។ គាត់សើចញឹមៗពោលថា:

– អស់លោកជាមិត្រនៃឈានល្បួឬ ? អញ្ជើញមកដល់ម៉ានទេវតើមានបំណងយ៉ាងណាដែរ? សូមអភ័យទោសដែលខ្ញុំមិនបានចេញទទួល !

ពោលចប់ ក៏លើកដៃស្វាគមន៍ « គៀវ » ។ ជនទាំងប្រាំបួនប្រញាប់លំឱនកាយគោរពតបវិញទាំងប្រុងប្រយ័ត្ន ព្រោះម្នាក់ ៗ ស្មានថាអម្បាញ់មិញសេរីយានទីដឹងថា ពួកខ្លួនឡើងមកដែរ តែដោយអាងថាមពលស្ដុកស្ដម្ភទើបមិនរវល់ ហើយពេលនេះគាត់លើកដៃស្វាគមន៍ប្រហែលជាល្បងបញ្ចេញកម្លាំងធាតុវាយលុកហើយ ម្ល៉ោះហើយម្នាក់ ៗ ខំចម្រើនកម្លាំងកាយការពារជីពចរ ឥតហ៊ានធ្វេស ។ ប៉ុន្តែតាមការពិតផ្ទុយស្រឡះ ដ្បិតអ្នកម្ចាស់ភ្នំម៉ានទ់ពុំបានគិតគូដល់ការវាយលុកឡើយ ។ ក្នុងចំណោមពួកទាំងនេះ តាចាស់ម្នាក់ពាក់អាវលឿងវែងតបថា:

– ពួកយើងខ្ញុំមកដល់ទីនេះដោយគ្មានសេចក្ដីអនុញ្ញាតពីលោកម្ចាស់ សូមមេត្តាអភ័យទោសផងចុះ ។

សេរីយានទីឃើញតាចាស់មានទឹកមុខស្លុតស្លាំង និយាយស្ដីដូចគ្មានកម្លាំងកំហែង ហើយហាក់មានជម្ងឺធ្ងន់ធ្ងរផង ក៏នឹកដល់មនុស្សម្នាក់ ។ គាត់ស្រែកភ្ញាក់សម្រុង:

– លោកជាគ្រូពេទ្យដៃឆើតនោះឬ ?

(នៅមានត)

Khmer Story Lovers

ដំកល់ទុកតាមលេខ ២៩២ ចុះថ្ងៃទី ១៨ - ៥ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់